UNESCO
United Nations
Educational, Scientific and
Cultural Organization

Global
Education
Monitoring
Report

**Press Release**

# យូណេស្កូរកឃើញថា ប្រទេស ៤០% ក្នុងចំណោមប្រទេសក្រីក្រជាងគេ ខកខាន ពុំបានជួយគាំទ្រដល់អ្នកសិក្សា ដែលប្រឈមនឹងហានិភ័យ ក្នុងអំឡុងវិបត្តិកូវីដ-១៩ និងជំរុញឱ្យមានការលើកកម្ពស់បរិយាបន្នក្នុងការអប់រំ

ទីក្រុងប៉ារីស ថ្ងៃទី ២៣ ខែ មិថុនា — មានប្រទេសមិនដល់ ១០% ឡើយ មានច្បាប់ដែលជួយធានាឱ្យមានការលើកកម្ពស់បរិយាបន្នឱ្យបានពេញលេញក្នុងការអប់រំ *នេះបើតាមរបាយការណ៍ពិនិត្យតាមដានការអប់រំជាសកល ឆ្នាំ ២០២០ ក្រោមប្រធានបទ៖ បរិយាបន្ន និងការអប់រំ –ទាំងអស់គ្នា មានន័យថាទាំងអស់គ្នា របស់យូណេស្កូ។*

របាយការណ៍នេះបង្ហាញពីការវិភាគស៊ីជម្រៅលើកត្តាសំខាន់ៗ ដែលនាំឱ្យមានការផាត់ចេញអ្នកសិក្សាក្នុងប្រព័ន្ធអប់រំទូទាំងប្រទេស ដូចជា ការផាត់ចេញដោយសារសារការអត្តសញ្ញាណ និងសមត្ថភាព (យេនឌ័រ អាយុ ទីតាំង ភាពក្រីក្រ ពិការភាព ជាតិពន្ធុ ជនជាតិដើមភាគតិច ភាសា សាសនា ស្ថានភាពចំណាកស្រុក ឬស្ថានភាពនៃការបាត់បង់ទីលំនៅ និន្នាការភេទ ឬការសម្តែងចេញនូវអត្តសញ្ញាណយេនឌ័រ ការជាប់ឃុំឃាំង ការប្រកាន់ជំនឿ និងការប្រកាន់អាកប្បកិរិយាអ្វីមួយជាដើម)។ របាយការណ៍នេះបានរកឃើញថា ការផាត់ចេញពីសេវាអប់រំកាន់តែមានសភាពធ្ងន់ធ្ងរមួយកម្រិតទៀត ក្នុងអំឡុងពេលនៃការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ និងធ្វើការប៉ាន់ប្រមាណថា មានប្រទេសចំណូលទាប និងប្រទេសចំណូលមធ្យមកម្រិតទាបប្រហែលជា ៤០% ពុំបានជួយគាំទ្រដល់សិស្សជួបការលំបាកក្នុងអំឡុងពេលមានការបិទទ្វារសាលារៀនជាបណ្តោះអាសន្នឡើយ។

របាយការណ៍ពិនិត្យតាមដានការអប់រំជាសកលឆ្នាំ ២០២០ បានជំរុញឱ្យប្រទេសនានាផ្តោតការយកចិត្តទុកដាក់លើអ្នកដែលត្រូវបានទុកចោល ខណៈពេលដែលសាលារៀនបើកទ្វារឡើងវិញ ដើម្បីឱ្យសង្គមកាន់តែធន់ទៅនឹងវិបត្តិនានា និងកាន់តែមានសមភាព។

Audrey Azoulay អគ្គនាយកនៃយូណេស្កូ មានប្រសាសន៍ថា “ដើម្បីតតាំងនឹងបញ្ហាប្រឈមដែលកំពុងកើតមានក្នុងជំនាន់របស់យើងនេះ ការបោះជំហានទៅរកការអប់រំដែលកាន់តែមានបរិយាបន្ន គឺជាអ្វីដែលចាំបាច់ដែលត្រូវធ្វើឱ្យខាងតែបាន។ ការគិតឡើងវិញពីអនាគតនៃការអប់រំ គឺជាអ្វីដែលរឹតតែមានសារៈសំខាន់ទៅទៀត ក្រោយការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ ព្រោះថាការរាតត្បាតនេះបានពង្រីកទំហំវិសមភាព និងធ្វើឱ្យឃើញកាន់តែច្បាស់ពីបញ្ហាវិសមភាព។ ការខកខានមិនធ្វើសកម្មភាពអ្វីនឹងបន្ថែមបង្អាក់ដល់ការសម្រេចបាននូវវឌ្ឍនភាពក្នុងសង្គម។”

**ការបន្តកើតឡើងនូវការផាត់ចេញពីការអប់រំ៖** របាយការណ៍នៅឆ្នាំនេះ គឺជារបាយការណ៍ពិនិត្យតាមដានការអប់រំជាសកលប្រចាំឆ្នាំលើកទី ៤ របស់យូណេស្កូ ដើម្បីតាមដានវឌ្ឍនភាពក្នុងការសម្រេចតាមចំណុចដៅនៃការអប់រំដែលត្រូវបានអនុម័ត ដោយរដ្ឋជាសមាជិកនៃអង្គការសហប្រជាជាតិក្នុងរបៀបវារៈអភិវឌ្ឍន៍ដោយចីរភាពឆ្នាំ ២០៣០ នៅក្នុងប្រទេសចំនួន ២០៩។ របាយការណ៍នេះកត់សម្គាល់ថា មានកុមារ និងយុវជនចំនួន ២៥៨ លាននាក់ ត្រូវបានផាត់ចេញទាំងស្រុងពីការអប់រំ ដោយភាពក្រីក្រគឺជាឧបសគ្គជាចម្បងដែលរារាំងពួកគេមិនឱ្យចូលរៀន។ ក្នុងប្រទេសចំណូលទាប និងចំណូលមធ្យម ក្មេងជំទង់មកពីគ្រួសារដែលមានជីវភាពធូរធារជាងគេ ២០% មានលទ្ធភាពបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិ បីដងច្រើនជាងក្មេងជំទង់មកពីគ្រួសារដែលមានជីវភាពក្រីក្រជាងគេ។ ក្នុងចំណោមកុមារដែលបានបញ្ចប់ការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ សិស្សមកពីគ្រួសារដែលមានជីវភាពធូរធារជាងគេ ទំនងជាមានបំណិនអាន និងបំណិនគណិតវិទ្យាកម្រិតមូលដ្ឋានពីរដងច្រើនជាងសិស្សមកពីគ្រួសារដែលមានជីវភាពក្រីក្រជាងគេ។ បើទោះបីជាមានការដាក់ចេញនូវចំណុចដៅបញ្ចប់ការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិឱ្យបានជាសកលត្រឹមឆ្នាំ ២០៣០ យ៉ាងណាក៏ដោយ កម្រមានស្ត្រីវ័យក្មេងដែលមានជីវភាពក្រីក្ររស់នៅ

តាមទីជនបទណាបានបញ្ចប់កម្រិតមធ្យមសិក្សា នៅក្នុងប្រទេសយ៉ាងហោចណាស់ចំនួន ២០ ដែលភាគច្រើនជាប្រទេសនៅតំបន់អាហ្វ្រិចសាប់សាហារ៉ា។

លើសពីនេះ បើតាមរបាយការណ៍នេះ សិស្សអាយុ ១០ ឆ្នាំ នៅក្នុងប្រទេសចំណូលមធ្យម និងចំណូលខ្ពស់ដែលទទួលបានការបង្រៀន ជាភាសាខុសពីភាសាកំណើតរបស់ពួកគេ ជាធម្មតាទទួលបានពិន្ទុក្នុងតេស្តអំណានទាបជាងសិស្សដែលនិយាយភាសាដើម ៣៤%។ ក្នុងប្រទេសចំណូលទាប និងចំណូលមធ្យមចំនួន ១០ កុមារមានពិការភាព ត្រូវបានរកឃើញថា អាចចេះអានស្ទាត់ជំនាញត្រឹមកម្រិតអប្បបរមា តិចជាងកុមារពុំមានពិការភាព ១៩%។ ឧទាហរណ៍នៅសហរដ្ឋអាមេរិក សិស្សដែលស្រឡាញ់ភេទដូចគ្នា ច្រើនតែនិយាយថា ពួកគេសុខចិត្តនៅផ្ទះមិនទៅរៀន ដោយសារមានអារម្មណ៍ពុំមានសុវត្ថិភាព ជិតបីដងច្រើនជាងសិស្សដែលមិនមែនជាអ្នកស្រឡាញ់ភេទដូចគ្នា។

**គ្រឹះដែលពុំមានសមធម៌៖** អមនឹងការចេញផ្សាយឯកសារនៅថ្ងៃនេះ ក្រុមរៀបចំរបាយការណ៍ពិនិត្យតាមដានជាសកលរបស់យូណេស្កូបានប្រកាសផ្សព្វផ្សាយនូវគេហទំព័រថ្មីមួយដែលមានឈ្មោះថា PEER ជាគេទំព័រដែលប្រមូលផ្តុំព័ត៌មានអំពីច្បាប់ និងគោលនយោបាយពាក់ព័ន្ធនឹងបរិយាបន្នក្នុងការអប់រំសម្រាប់គ្រប់ទេសទាំងអស់នៅក្នុងពិភពលោក។ គេហទំព័រ PEER បង្ហាញថាប្រទេសជាច្រើននៅបន្តបែងចែកសិស្សទៅតាមប្រភេទខុសៗគ្នា ដែលជាកត្តាធ្វើឱ្យការប្រកាន់ផ្នត់គំនិត ការរើសអើង និងការចាត់ទុកសិស្សក្រុមណាមួយថាជាក្រុមដោយឡែក កាន់តែមានកម្រិតធ្ងន់ធ្ងរបន្ថែមទៀត។ ច្បាប់នៅក្នុងប្រទេសមួយភាគបួនក្នុងចំណោមប្រទេសទាំងអស់តម្រូវឱ្យកុមារមានពិការភាពទទួលបានការអប់រំនៅកន្លែងដាច់ដោយឡែកពីគ្នា ដែលតួលេខនេះកើនឡើងដល់ ៣០% នៅអាមេរិកឡាទីន និងការ៉ាបៀន ក៏ដូចជា នៅអាស៊ី។

**ការផាត់ចេញយ៉ាងច្បាស់ក្រឡែត៖** ប្រទេសចំនួនពីរនៅអាហ្វ្រិចនៅតែហាមឃាត់មិនឱ្យក្មេងស្រីដែលមានផ្ទៃពោះចូលរៀន ប្រទេសចំនួន ១១៧ អនុញ្ញាតឱ្យមានការអាពាហ៍ពិពាហ៍កុមារ ខណៈពេលដែលប្រទេសចំនួន ២០ មិនទាន់ផ្តល់សច្ចាប័នដល់*អនុសញ្ញាលេខ ១៣៨* របស់អង្គការអន្តរជាតិខាងការងារដែលដាក់បម្រាមលើពលកម្មកុមារ។ នៅតាមប្រទេសជាច្រើននៅអឺរ៉ុបកណ្តាល និងអឺរ៉ុបភាគខាងកើត កុមារជនជាតិរ៉ូម៉ា ត្រូវបានគេបំបែកឱ្យរៀនដាច់ដោយឡែកពីកុមារផ្សេងទៀតនៅក្នុងសាលារៀនទូទៅ។ នៅអាស៊ី ក្រុមមនុស្សដែលគ្មានទីលំនៅ ដូចជា ជនជាតិរ៉ូហ៊ីងយ៉ាជាដើម បានទទួលការបង្រៀននៅក្នុងប្រព័ន្ធអប់រំដាច់ដោយឡែក ស្របជាមួយនឹងប្រព័ន្ធអប់រំទូទៅ។ ក្នុងប្រទេស OECD សិស្សជាងពីរភាគបីមកពីគ្រួសារអន្តោប្រវេសន៍រៀននៅសាលាដែលចំនួនសិស្សអន្តោប្រវេសន៍ស្មើនឹងយ៉ាងហោចណាស់ ៥០% នៃចំនួនសិស្សសរុប ដែលជាកត្តាកាត់បន្ថយឱកាសទទួលបានជោគជ័យក្នុងការសិក្សារបស់ពួកគេ។

Manos Antoninis ប្រធានទទួលបន្ទុកការរៀបចំរបាយការណ៍ពិនិត្យតាមដានការអប់រំជាសកលមានប្រសាសន៍ថា "ជំងឺកូវីដ-១៩ បានផ្តល់ឱកាសពិតប្រាកដឱ្យយើងធ្វើការគិតសាជាថ្មីពីប្រព័ន្ធអប់រំរបស់យើង។ ប៉ុន្តែការបោះជំហានទៅរកពិភពលោកមួយដែលផ្តល់តម្លៃ និងស្វាគមន៍ភាពចម្រុះ នឹងមិនមែនកើតឡើង ភ្លាមៗនោះឡើយ។ មានភាពតានតឹងជាក់ស្តែងរវាងការបង្រៀនកុមារក្រោមដំបូលតែមួយ និងការបង្កើតបរិយាកាសដែលធ្វើឱ្យសិស្សអាចរៀនបានល្អបំផុត ប៉ុន្តែជំងឺកូវីដ-១៩ បានបង្ហាញយើងថា យើងនៅតែមានឱកាសធ្វើសកម្មភាពខុសប្លែកពីមុន ប្រសិនបើយើងបន្តគិតពិចារណាពីចំណុចនេះ"។

ការប្រកាន់ជំនឿប្រកបដោយការរើសអើងរបស់ឪពុកម្តាយ ត្រូវបានរកឃើញថាជាឧបសគ្គមួយដែលរារាំងដល់បរិយាបន្ន៖ ឪពុកម្តាយប្រមាណ ១៥% នៅក្នុងប្រទេសអាល្លឺម៉ង់ និង ៥៩% នៅហុងកុងប្រទេសចិន ខ្លាចកុមារមានពិការភាពបង្កការរំខានដល់ការរៀនសូត្ររបស់កុមារផ្សេងទៀត។ ឪពុកម្តាយដែលមានកូនងាយរងគ្រោះ ក៏មានបំណងបញ្ជូនកូនទៅរៀននៅក្នុងសាលារៀន ដែលអាចធានាបាននូវសុខុមាលភាពរបស់គេ និងឆ្លើយតបចំពោះតម្រូវការរបស់ពួកគេផងដែរ។ នៅ Queensland ប្រទេសអូស្ត្រាលី សិស្ស ៣៧% ក្នុងសាលារៀនពិសេសគឺជាសិស្សដែលបានផ្លាស់ចេញពីសាលារៀនទូទៅ។

របាយការណ៍នេះបង្ហាញថា ជារឿយៗ ប្រព័ន្ធអប់រំខកខានពុំបានពិចារណាពីតម្រូវការពិសេសរបស់អ្នកសិក្សានោះឡើយ។ មានប្រទេសតែ ៤១ ប៉ុណ្ណោះ នៅទូទាំងសកលលោក ដែលទទួលស្គាល់ភាសាសញ្ញាជាផ្លូវការ ហើយនៅក្នុងសកលលោកទាំងមូលសាលារៀនចង់បានការភ្ជាប់អ៊ីនធឺណែតប្រើប្រាស់ ជៀសជាងបំពេញទៅតាមតម្រូវការរបស់សិស្សមានពិការ

ភាព។ ក្មេងស្រីប្រមាណ ៣៣៥ លាននាក់ រៀននៅក្នុងសាលារៀនដែលពុំបានផ្តល់ឱ្យពួកគេនូវទឹក និងសេវាអនាម័យដែលពួកគេត្រូវការ ដើម្បីបន្តរៀនក្នុងពេលមានរដូវ។

**អ្នកសិក្សាដែលមានលក្ខណៈខុសប្លែកពីគេ៖** នៅពេលដែលព័ត៌មានរបស់អ្នកសិក្សាពុំបានបញ្ចូលឱ្យបានគ្រប់គ្រាន់ក្នុងកម្មវិធីសិក្សា និងសៀវភៅសិក្សា ពួកគេមានអារម្មណ៍ថាពួកគេគឺជាមនុស្សមកពីក្រុមប្លែកពីគ្នា។ មានការលើកឡើងពីក្មេងស្រី និងស្ត្រីត្រឹមតែ ៤៤% ប៉ុណ្ណោះនៅក្នុងសៀវភៅសិក្សាភាសាអង់គ្លេសកម្រិតមធ្យមសិក្សាក្នុងប្រទេសម៉ាឡេស៊ី និងឥណ្ឌូនេស៊ី ៣៧% ក្នុងប្រទេសបង់ក្លាដេស និង ២៤% ក្នុងខេត្តពន់ចាបប្រទេសប៉ាគីស្ថាន។ កម្មវិធីសិក្សានៅក្នុងប្រទេស ២៣ ក្នុងចំណោមប្រទេសអឺរ៉ុបចំនួន ៤៩ ពុំបានឆ្លើយតបចំពោះបញ្ហានិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ឬការសម្តែងចេញអំពីយេនឌ័រនោះឡើយ។

គ្រូត្រូវការ និងចង់បានការបណ្តុះបណ្តាលអំពីបរិយាបន្ន ហើយក្នុងចំណោមគ្រូបឋមសិក្សា ១០ នាក់ក្នុងប្រទេសប្រើភាសាបារាំងចំនួន ១០ នៅអាហ្វ្រិចសាប់សាហារ៉ា មានតិចជាង ១ នាក់ប៉ុណ្ណោះ ដែលនិយាយថា ពួកគេបានទទួលការបណ្តុះបណ្តាលបែបនេះ។ គ្រូមួយភាគបួននៅក្នុងប្រទេសចំនួន ៤៨ បានលើកឡើងថា ពួកគេចង់បានការបណ្តុះបណ្តាលបន្ថែមទៀតអំពីរបៀបបង្រៀនសិស្សដែលមានតម្រូវការពិសេស។

**ការបន្តខ្វះទិន្នន័យដែលមានគុណភាពអំពីអ្នកដែលត្រូវបានគេទុកចោល៖** ប្រទេសដែលមានចំណូលទាប និងចំណូលមធ្យមប្រមាណពាក់កណ្តាលពុំបានប្រមូលទិន្នន័យអប់រំឱ្យបានគ្រប់គ្រាន់អំពីកុមារមានពិការភាពនោះឡើយ។ ការអង្កេតតាមខ្នងផ្ទះគឺជាគន្លឹះដើម្បីបំបែកទិន្នន័យលម្អិតទៅតាមលក្ខណៈរបស់បុគ្គលម្នាក់ៗ។ ប៉ុន្តែ មានប្រទេសចំនួន ៤១% ដែលគ្របដណ្តប់លើប្រជាជន ១៣% ក្នុងចំណោមប្រជាជនសរុបក្នុងពិភពលោក ពុំបានធ្វើការអង្កេត ឬបើកចំហទិន្នន័យដែលបានពីការអង្កេតទាំងនេះនោះឡើយ។ តួលេខស្ថិតិពីការសិក្សាភាគច្រើនយកបានពីសាលា ដោយពុំបានពិចារណាពីអ្នកដែលមិនបានមករៀននោះឡើយ។

Antoninis មានប្រសាសន៍ថា "ការពុំមានទិន្នន័យគ្រប់គ្រាន់ មានន័យថាយើងយើងពុំបានមើលឃើញផ្នែកដ៏ធំមួយនៃរូបភាពជារួម។ ដូច្នេះ ទើបយើងមានការភ្ញាក់ផ្អើល ពេលដែលបញ្ហាសមភាពត្រូវបានស្តែងចេញភ្លាមៗក្នុងអំឡុងពេលនៃជំងឺកូវីដ-១៩ បែបនេះ"។

**សញ្ញាដែលបង្ហាញពីវឌ្ឍនភាពឆ្ពោះទៅរកបរិយាបន្ន៖** របាយការណ៍នេះ និងគេហទំព័រ PEER កត់សម្គាល់ថា មានប្រទេសជាច្រើនកំពុងប្រើប្រាស់គោលវិធីបែបវិជ្ជមាន និងនវានុវត្តន៍ដើម្បីបោះជំហានទៅរកបរិយាបន្ន។ ប្រទេសជាច្រើនកំពុងបង្កើតមជ្ឈមណ្ឌលធនធានសម្រាប់សាលារៀនជាច្រើន និងផ្តល់លទ្ធភាពឱ្យគ្រឹះស្ថានសិក្សាទូទៅអាចបង្កភាពងាយស្រួលដល់កុមារមកពីសាលាពិសេស ដូចជា នៅក្នុងប្រទេសម៉ាឡាវី គុយបា និងអ៊ុយក្រែនជាដើម។ ប្រទេសហ្វាំងឡង់ ញូហ្សេឡែន និងសាម៉ៅ ក៏កំពុងប្រើប្រាស់គ្រូចល័តដើម្បីចុះទៅបង្រៀនដល់ក្រុមសិស្សដែលពុំបានទទួលសេវាផងដែរ។

ប្រទេសជាច្រើនក៏ត្រូវបានគេមើលឃើញថា កំពុងងាកចេញពីការអនុវត្តកន្លងមកដើម្បីឆ្លើយតបទៅនឹងតម្រូវការខុសៗគ្នារបស់អ្នកសិក្សាផងដែរ៖ ឧទាហរណ៍ រដ្ឋ Odisha ក្នុងប្រទេសឥណ្ឌា ប្រើប្រាស់ភាសាកុលសម្ព័ន្ធចំនួន ២១ ភាសានៅក្នុងថ្នាក់រៀន, ប្រទេសកេនយ៉ាបានកែសម្រួលកម្មវិធីសិក្សារបស់ខ្លួនឱ្យស្របតាមប្រតិទិនពនេចររបស់ប្រជាពលរដ្ឋ និងក្នុងប្រទេសអូស្ត្រាលី កម្មវិធីសិក្សាសម្រាប់សិស្ស ១៩% ត្រូវបានគ្រូកែសម្រួល ដើម្បីឱ្យលទ្ធផលរំពឹងទុកអាចបន្សុីទៅនឹងតម្រូវការរបស់សិស្ស។

របាយការណ៍នេះមានបញ្ចូលសម្ភារសម្រាប់យុទ្ធនាការឌីជីថល ក្រោមប្រធានបទ ទាំងអស់គ្នា មានន័យថា ទាំងអស់គ្នា ដែលផ្សព្វផ្សាយពីអនុសាសន៍សំខាន់ៗមួយចំនួនសម្រាប់រយៈពេល ១០ ទៀត។

****

សម្រាប់ព័ត៌មានបន្ថែម b-roll រូបថត ការសម្ភាស វីដេអូ និងរូបជីវចល សូមទាក់ទងឈ្មោះ Kate Redman អ៊ីម៉ែល៖ k.redman@unesco.org និងទូរស័ព្ទ៖ +33(0)671786234

**កំណត់សម្គាល់ចំពោះនិពន្ធនាយក**

សូមចូលមើល កញ្ចប់សម្រាប់អ្នកសារព័ត៌មានតាមប្រព័ន្ធអេឡិចត្រូនិច ដែលមានផ្ទុករបាយការណ៍ និងរូបភាពសំឡេងវីដេអូមួយចំនួន។ **[លេខសម្ងាត់៖ AllmeansAll]**

របាយការណ៍ពិនិត្យតាមដានការអប់រំជាសកលត្រូវបានរៀបចំឡើងដោយក្រុមអ្នកជំនាញឯករាជ្យ និងបោះពុម្ពផ្សាយដោយយូណេស្កូ។ ក្រុមនេះមានភារកិច្ចផ្លូវការពិនិត្យតាមដានវឌ្ឍនភាពក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍ដោយចីរភាព ដែលផ្តោតលើការអប់រំពោលគឺគោលដៅអភិវឌ្ឍន៍ដោយចីរភាពទី ៤។

គេហទំព័រ PEER នឹងអាចចូលមើលជាសាធារណៈចាប់ពីថ្ងៃទី ២៣ ខែ មិថុនា តទៅ។ មុនថ្ងៃនោះ អ្នកសារព័ត៌មានអាចចូលទៅក្នុងគេហទំព័រនេះ ដោយប្រើលេខសម្ងាត់ដូចតទៅ៖

- https://www.education-profiles.org
- Username: team
- Password: gemprofiles246!